*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

# លទ្ធភាពរកការងាររបស់និស្សិតក្រោយបញ្ចប់ការសិក្សា ក្នុងឆ្នាំ ២០១៩ និង២០២០

TAK Kean *
Vice-Rector, Royal University of Phnom Penh, Russian Federation Boulevard, Toul Kork, Phnom Penh, Cambodia
*Corresponding Author: TAK Kean (kean.tak@rupp.edu.kh)

**To cite this article:** Kean, T. (2020) **លទ្ធភាពរកការងាររបស់និស្សិតក្រោយបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០១៩ និង២០២០**. *Cambodia Journal of Basic and Applied Research (CJBAR), 2(2-1)*, 01–16.

## សេចក្តីផ្តើម

ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់អតីតនិស្សិតផ្នែកSTEM បានរៀបចំធ្វើឡើង ក្រោមគម្រោង (HEIP-RUPP) ដើម្បីពិនិត្យតាមដានអំពីប្រសិទ្ធភាពការអប់រំ បណ្តុះបណ្តាលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈការិយាល័យធានាគុណភាពរបស់គ្រឹះស្ថាន ដោយផ្តោតទៅលើអតីតនិស្សិតសិក្សាផ្នែក STEM ក្នុងកម្រិតបរិញ្ញាបត្រទាំងអាហារូបករណ៍និងនិស្សិតសិក្សាបង់ថ្លៃ ដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ ២០១៩ និង២០២០។ គោលបំណងចំបងនៃការសិក្សានេះគឺដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីលទ្ធភាពទទួលបានការងារធ្វើរបស់អតីតនិស្សិត ស្ថិរភាពការងារ និងអត្ថប្រយោជន៍មុខវិជ្ជាដែលពួកគាត់បានសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានជួយដល់និស្សិតទទួលបានការងារដំបូងបែបណា និងប្រាក់បៀវត្សក្នុងកម្រិតប៉ុណ្ណា។លើសពីនេះការស្រាវជ្រាវនេះ គឺបង្ហាញពីប្រសិទ្ធភាពនៃការបណ្តុះបណ្តាលផ្នែកSTEM និងទំនាក់ទំនងរវាងកម្មវិធីសិក្សា( និងមុខវិជ្ជា )នឹងតម្រូវការទីផ្សារការងារ និងគុណភាពដែលឆ្លើយតបនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ។

បន្ថែមលើការសិក្សាស្រាវជ្រាវនេះ យើងអាចបង្កើតជាវិធានពិនិត្យតាមដាន វាយតម្លៃសកម្មភាពរបស់សាកលវិទ្យាល័យជាប្រចាំ ហើយរបកគំហើញនៃលទ្ធផលសិក្សានឹងជួយសាកលវិទ្យាល័យឱ្យកំណត់ប្រសិទ្ធភាព និងប្រសិទ្ធផល កំណត់ចំណុចខ្លាំងនិងចំណុចត្រូវកែលម្អក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ និងទំនាក់ទំនងរវាងការអប់រំបណ្តុះបណ្តាលជាមួយនឹងតម្រូវការទីផ្សារការងារ។ យោងទៅលើកត្តាចាំបាច់ទាំងនេះ ការកំណត់វិធីសាស្ត្រស្រាវជ្រាវដែលនាំទៅរកការឆ្លើយតបទៅនឹងសារៈសំខាន់នៃការស្រាវជ្រាវខាងក្រោម នឹងអាចជួយបង្កើនការយល់ដឹងអំពីស្ថានភាពនិស្សិតបានកាន់តែច្បាស់ទាំងលើការសិក្សាក្នុងគ្រឹះស្ថាននិងលទ្ធភាពរកការងាររបស់និស្សិត។

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

## សារៈសំខាន់នៃការសិក្សា

សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ជាគ្រឹះស្ថានសាធារណៈដែលយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលនិស្សិតថ្នាក់បរិញ្ញាបត្រសម្រាប់និស្សិតចង់ក្លាយជាគ្រូបង្រៀននិងអ្នកដឹកនាំក្នុងវិស័យអប់រំ សម្រាប់សាកលវិទ្យាល័យ មហាវិទ្យាល័យ និងស្ថាប័នសាធារណៈដទៃទៀតដើម្បីរួមចំណែកបង្កើតធនធានមនុស្សដែលមាន គុណភាពខ្ពស់ស្របតាមស្តង់ដាជាតិ តំបន់ និងអន្តរជាតិ និងសមត្ថភាពឆ្លើយតបតម្រូវការទីផ្សារការងារ។ កន្លងមកសាធារណៈជនតែងតែយល់ថាការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញអាចក្លាយជាគ្រូបង្រៀនតែប៉ុណ្ណោះ ដូច្នេះដើម្បីទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីស្ថានភាពការងាររបស់អតីតនិស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់នោះ និងការប្រើប្រាស់សមត្ថភាពនិងជំនាញដែលទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ការសិក្សាបែបនេះអាចជាមូលដ្ឋានវិភាគលើកត្តាសំខាន់ដែលជះឥទ្ធិពលទៅលើបេសកកម្មរបស់មហាវិទ្យាល័យ ដេប៉ាតឺម៉ង់ និងកម្មវិធីសិក្សានានា ហើយលទ្ធផលដែលទទួលបានអាចមូលដ្ឋានសម្រាប់កែលម្អកម្មវិធីសិក្សា(មុខវិជ្ជា)ឲ្យបានសមស្របនឹងតម្រូវការទីផ្សារការងារផងនិងដើម្បីឆ្លើយតបនិងក្របខណ្ឌគុណវុឌ្ឍិជាតិផងដែរ។

ជាមួយគ្នានេះ របកគំហើញដែលទទួលបានពីការស្រាវជ្រាវនេះគឺជាធាតុចូលសម្រាប់វាស់វែងគុណភាពអប់រំដែលផ្តល់ដោយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ តាមរយៈភាពជោគជ័យក្នុងវិស័យការងារ ស្ថិរភាពការងារ ប្រាក់បៀវត្ស និងការប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការសិក្សាក្នុងជំនាញឯកទេស។ ដូច្នេះការសិក្សានេះ គឺផ្តោតទៅលើកត្តាមួយចំនួនដូចខាងក្រោម៖

- កត្តាជះឥទ្ធិពលលើការងារដូចជា ភេទ និងឯកទេសជំនាញនិងតម្រូវការទីផ្សារការងារដែលធ្វើឱ្យនិស្សិតទទួលបានជោគជ័យ។
- ទំនាក់ទំនងរវាងការអប់រំក្នុងផ្នែកSTEM និងការយល់ដឹងអំពីការងារទីផ្សារដែលបុគ្គលម្នាក់ៗ រំពឹងទុកដូចជា៖ ការពេញចិត្តចំពោះការងារ ការរំពឹងទុកអំពីប្រាក់ចំណូល និងស្ថិរភាពការងារ។
- ការស្វែងយល់ពីរបៀបរកការងារធ្វើក្នុងចន្លោះក្រោយពេលបញ្ចប់ការសិក្សា។
- ការប្រើប្រាស់ចំណេះដឹង បទពិសោធន៍នៃការយល់ដឹង និងទស្សនៈផ្ទាល់ខ្លួនរបស់និស្សិតក្នុងការវាយតម្លៃលើកម្មវិធីសិក្សា ដើម្បីធ្វើជាមូលដ្ឋានវិភាគសម្រាប់កែលម្អកម្មវិធីសិក្សាក្នុងពេលអនាគត។
- ការប្រៀបធៀបលទ្ធផលរំពឹងទុកនៃកម្មវិធីសិក្សាជាមួយក្របខណ្ឌគុណវុឌ្ឍិជាតិ។

## វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីទទួលបានលទ្ធផលសម្រាប់បកស្រាយដែលអាចទុកចិត្តបាន យើងបានប្រើប្រាស់វិធីសាស្ត្រតាមបែបវិភាគស្ថិតិនិងវិធីសាស្ត្រវិភាគទិន្នន័យ ដោយប្រើប្រាស់កម្រងសំណួរជាឧបករណ៍សម្រាប់ប្រមូលព័ត៌មាននិង

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

ទិន្នន័យដែលទាក់ទងនឹងអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០១៩ និង២០២០។ កម្រងសំណួរដែលប្រើប្រាស់សម្រាប់សម្ភាសបានចែកចេញជាប្រាំផ្នែកធំៗ ដែលផ្នែកទី១ពាក់ព័ន្ធព័ត៌មាននិស្សិតដែលផ្តោតចំបងលើភេទ កន្លែងរស់នៅសព្វថ្ងៃ ជំនាញដែលសិក្សា។ ផ្នែកទី២ ទាក់ទងបទពិសោធន៍ការងារក្នុងពេលសិក្សាក្នុងគ្រឹះស្ថាន ផ្នែកទី៣ទាក់ទងនឹងស្ថានភាពការងារក្រោយពេលបញ្ចប់ការសិក្សា ផ្នែកទី៤គឺផ្តោតលើទស្សនៈនិស្សិតអំពីការសិក្សានិងតម្រូវការទីផ្សារការងារ ហើយផ្នែកទី៥គឺការស្វែងយល់ពីការសិក្សាពេញមួយជីវិត។ កម្រងសំណួរបានបំលែងជា Google Form ហើយបានផ្ញើ link ទៅឲ្យនិស្សិត៥៤៨នាក់(Testing Sample Proportion, **p̂=548)** ដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ ២០១៨ តាមរយៈEmail ដើម្បីប្រាកដថាកម្រងសំណួរទាំងនោះជាឧបករណ៍សម្រាប់ប្រមូលព័ត៌មានដែលចង់បានពិតប្រាកដ។ ក្នុងការសាកល្បងកម្រងសំណួរនោះ យើងរកឃើញថាវិធីបែបនេះប្រើប្រាស់ពេលវេលាច្រើនហើយលទ្ធផលបានតិច(តែ៦%ប៉ុណ្ណោះ) ដែលអាចធ្វើសេចក្តីសន្និដ្ឋានបានថាការប្រមូលព័ត៌មាននិងទិន្នន័យបែបនេះមិនសូវមានប្រសិទ្ធភាព។

តាមរយៈការសាកល្បងកម្រងសំណួរ យើងបានសម្រេចជ្រើសរើសប្រើប្រាស់លេខទូរស័ព្ទសម្រាប់ទំនាក់ទំនងអតីតនិស្សិតទាំងនោះតាមទំហំសំណាក។ ការទំនាក់ទំនងតាមលេខទូរស័ព្ទមានការលំបាកខ្លះដោយសារតែមានលេខទូរស័ព្ទជាច្រើនបានផ្លាស់ប្តូរដែលធ្វើឱ្យយើងជ្រើសរើសសំណាកតាមបែបចៃដន្យ(Stratified random Sampling)។ ក្នុងន័យនេះការកំណត់ទំហំគំរូតាងដែលអាចទុកចិត្ត៩៥% និងត្រូវបានគណនាយ៉ាងហ្មត់ចត់ដើម្បីឲ្យគំរូតាងតំណាងឱ្យអ្នកបានបញ្ចប់ការសិក្សាមានភាពសុក្រិតដោយផ្អែកលើកម្រិតលំអៀង៥% ។

ការប្រមូលទិន្នន័យធ្វើឡើងតាមរយៈមធ្យោបាយមួយចំនួនដូចជាការប្រើប្រាស់លេខទូរស័ព្ទ Telegram និង Online(Google Form)។ ក្នុងនោះយើងបានណែនាំក្រុមអ្នកប្រមូលព័ត៌មានអំពីនីតិវិធីធ្វើបទសម្ភាសន៍យ៉ាងត្រឹមត្រូវនិងមានការត្រួតពិនិត្យយ៉ាងហ្មត់ចត់ ដើម្បីប្រាកដថាពួកអ្នកប្រមូលព័ត៌មានទាំងនោះមានសមត្ថភាពសម្ភាសបានល្អនិងចេះប្រមូលព័ត៌មានដែលចាំបាច់។ ក្នុងពេលដែលក្រុមអ្នកសម្ភាសន៍ចេញធ្វើសម្ភាសដោយម្ចាស់ការហើយ ការិយាល័យធានាគុណភាពបានតាមពិនិត្យផ្ទៀងផ្ទាត់លទ្ធផលទិន្នន័យយ៉ាងយកចិត្តទុកដាក់ ដើម្បីដឹងច្បាស់ថាព័ត៌មានដែលប្រមូលបានពីការស្រាវជ្រាវនេះអាចជាព័ត៌មានដែលជឿទុកចិត្តបាន។ ក្រោយពីអ្នកចូលរួម បានយល់ព្រមផ្តល់ព័ត៌មានហើយ ក្រុមអ្នកសម្ភាសន៍បានផ្ញើកម្រងសំណួរមានទម្រង់ជា Google Form ទៅឲ្យអតីតនិស្សិតតាមរយៈTelegram ហើយបានសុំឲ្យអ្នកចូលរួមបំពេញព័ត៌មានចប់សព្វគ្រប់ ត្រូវថតកម្រងសំណួរទំព័រចុងក្រោយផ្ញើមកក្រុមអ្នកសម្ភាសន៍វិញ។

សាកលវិទ្យាល័យភូមិន្ទភ្នំពេញមាននិស្សិតទទួលបានអាហារូបករណ៍ប្រមាណជា២០% និងនិស្សិតសិក្សាបង់ថ្លៃប្រមាណជា៨០%។ ផ្អែកលើបំណែកគំរូតាង**២៧៩៥**សំណាក (Sample Proportion, **p̂=2795)** ដែល

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

បានបញ្ចប់ការសិក្សាឆ្នាំ២០១៩និង២០២០ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ យើងបានកំណត់យកទំហំគំរូតាង៨៦៦សំណាក តាមការជ្រើសរើសបែបចៃដន្យ(Stratified random Sampling) ពោលគឺស្មើនឹង ៦០%នៃបំណែកគំរូតាង(Sample Proportion) នៃកម្រិតទុកចិត្ត៩៥%និងកម្រិតលំអៀង៥% ។

ដើម្បីប្រមូលទិន្នន័យ ការិយាល័យធានាគុណភាពបានចាប់ផ្តើមប្រមែប្រមូលព័តមានទំនាក់ទំនងរបស់និស្សិតដែលបានបញ្ចប់ការសិក្សាទាំងអស់ពីតាមការិយាល័យសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។ នៅដើមខែកញ្ញាយើងចាប់ផ្តើមសាកល្បងកម្រងសំណួរមុននឹងត្រូវយកទៅអនុវត្តក្នុងការប្រមូលព័ត៌មាន និងដើម្បីធានាថាលទ្ធផលដែលប្រមូលបានអាចបំពេញគោលបំណងនៃការសិក្សានិងរបកគំហើញដែលអាចទទួលយកបានស្របតាមអ្វីដែលយើងចង់ស្វែងរក ហើយដើមខែវិច្ឆិកា យើងបានរើសអ្នកសម្ភាសន៍យកមកបណ្តុះបណ្តាលមុនដំណើរការប្រមូលទិន្នន័យ។ គួរកត់សម្គាល់ថាការស្រាវជ្រាវនេះពឹងផ្អែកទៅលើការទំនាក់ទំនងតាមទូរស័ព្ទ Telegram និងOnline(Google Form) ដោយមើលឃើញថាសារអេឡិចត្រូនិកតែមួយមិនអំណោយផលដល់និស្សិតដែលរស់នៅតាមតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជាទេ ហើយការប្រើប្រាស់ប្រព័ន្ធទំនាក់ទំនងតាមទូរស័ព្ទ រួមជាមួយTelegram និងOnline(Google Form) អាចជួយឲ្យយើងសន្សំថវិកា និងពេលវេលាបានច្រើន ហើយលទ្ធផលក៏អាចទុកចិត្ត ដោយសារអ្នកផ្តល់ចម្លើយមានពេលគ្រប់គ្រាន់ក្នុងការផ្តល់ចម្លើយត្រឡប់មកវិញ។ សំណួរដែលប្រើប្រាស់ក្នុងការប្រមូលទិន្នន័យនេះ ភាគច្រើនតម្រូវឱ្យអ្នកឆ្លើយផ្តល់និទស្សន៍ ចំណែកចម្លើយដែលទទួលបានជាពាក្យពេចន៍ត្រូវបានបំលែងជាលេខកូដមុនបញ្ចូលក្នុងប្រព័ន្ធ SPSS សម្រាប់ធ្វើការវិភាគ ។

# លទ្ធផលសិក្សានិងការវិភាគទិន្នន័យ

## លទ្ធផលអ្នកចូលរួមផ្តល់ព័ត៌មាន

ការសិក្សាអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់អតីតនិស្សិតផ្នែកSTEMដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញក្នុងឆ្នាំ២០១៩ និង២០២០។ ការស្រាវជ្រាវនេះ គឺសិក្សាលើក្រុមនិស្សិតថ្នាក់បរិញ្ញាបត្រអាហារូបករណ៍និងសិក្សាបង់ថ្លៃ ដែលមានគំរូតាងចំនួន៨៦៦សំណាក និស្សិតប្រុស៦៣.៣%និង និស្សិតស្រី៣៦.៧% ដែលតំណាងឲ្យអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩ចំនួន១៥៦២ នាក់ (Sample Proportion **p̂=1562**) និងឆ្នាំ២០២០ចំនួន៧១៨នាក់(Sample Proportion **p̂=718**) សរុបទាំងអស់២២៨០នាក់ (population size =2280)។ អ្នកចូលរួមក្នុងការសិក្សានេះមកពីផ្នែកSTEM ដែលមានមហាវិទ្យាល័យវិទ្យាសាស្ត្រចំនួន៩៣.៣%(n=866) និងមហាវិទ្យាល័យវិស្វកម្មចំនួន៦.៧% (n=866)។ ចម្លើយដែលទទួលបានទាំងនោះមាននិស្សិតអាហារូបករណ៍ចំនួន១៧.២%(n=866) និស្សិតស្រី២១.៧% និងសិក្សាបង់ថ្លៃចំនួន៨២.៨% (n=866) និស្សិតស្រី៧៨.៣% ហើយអតីតនិស្សិតទាំងនោះ

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

កំពុងបម្រើការទូទាំង ២៥ ខេត្តក្រុងក្នុងប្រទេសកម្ពុជា។ ការសិក្សានេះបានបង្ហាញថា អតីតនិស្សិតភាគច្រើន (៥៧%) កំពុងរស់នៅនិងបម្រើការក្នុងរាជធានីភ្នំពេញ។

តាមទិន្នន័យដែលទទួលបាន បង្ហាញឲ្យឃើញថា អតីតនិស្សិតរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានកំពុងបម្រើការងារក្នុងវិស័យនានាទូទាំង២៥ខេត្តក្រុងនៃព្រះរាជាណាចក្រកម្ពុជា។




ក្រាហ្វិក 1៖ ទីកន្លែងអតីតនិស្សិតសភភពប្រកបការងារតាម ខេត្តនិងក្រុង

រូបភាព 1 ៖ គំរូតាងអ្នកចូលរួម




អ្នកចូលរួមផ្ដល់ព័ត៌មានអំពីលទ្ធភាពមានការងារធ្វើមានអាយុចន្លោះពី២០ឆ្នាំទៅ២៥ឆ្នាំ។ ផ្អែកលើទិន្នន័យដែលទទួលបាននោះបង្ហាញថា ក្រុមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩ អាយុចន្លោះពី២០ឆ្នាំទៅ២៥ឆ្នាំ មានចំនួន៩១.៤% រីឯក្រុមនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២០ អាយុចន្លោះពី

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

២០ឆ្នាំទៅ២៥ឆ្នាំ មានចំនួន៩៧.៣% មកពីមហាវិទ្យាល័យវិទ្យាសាស្ត្រចំនួន៩១.៧% (n=808) និងមហាវិទ្យាល័យវិស្វកម្មចំនួន៩៨.៣%(n=58)។

## ការប្រៀបធៀបអំពីស្ថានភាពការងារនិស្សិតក្នុងពេលកំពុងសិក្សា

តាមការសិក្សាបង្ហាញថា និស្សិតមានការងារធ្វើក្នុងពេលសិក្សាកំឡុងពេលកំពុងរៀនភាគច្រើនជានិស្សិតឆ្នាំទី៣ ក្នុងនោះអតីតនិស្សិតរៀនចប់ក្នុងឆ្នាំ២០១៩(n=756) ចំនួន២៣.៩% និងនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២០(n=110)ចំនួន២១.៨%។ តាមការវិភាគទិន្នន័យដែលផ្តល់ដោយអ្នកចូលរួម បានបង្ហាញថាមុនចូលសិក្សារបស់ក្រុមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩ចំនួន១៦.៣%មានការងារធ្វើរួចហើយ ចំណែកក្រុមនិស្សិតរៀនចប់ក្នុងឆ្នាំ២០២០ចំនួន២០.៩%បានអះអាងថាមានការងារធ្វើរួចហើយដែរ។

ផ្អែកលើទិន្នន័យខាងក្រោម យើងអាចសន្និដ្ឋានថាពេលបានចូលមកសិក្សាក្នុងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតបានស្វែងរកការងារធ្វើទៅតាមលទ្ធភាពរបស់ពួកគេ ហើយនៅឆ្នាំទី៤ជាឆ្នាំបញ្ចប់ ចំនួនមានការងារធ្វើក្នុងពេលសិក្សាមានការថយចុះមកវិញដែលជាសញ្ញាណបង្ហាញថានិស្សិតបានងាកមកផ្តោតលើការសិក្សាដើម្បីប្រឡងបញ្ចប់។




| | ឆ្នាំទី១ | ឆ្នាំទី២ | ឆ្នាំទី៣ | ឆ្នាំទី៤ |
|---|---|---|---|---|
| ឆ្នាំ២០១៩ (n=756) | 13.6% | 19.6% | 23.9% | 15.3% |
| ឆ្នាំ២០២០(n=110) | 20% | 17.3% | 21.8% | 16.4% |

ក្រាហ្វិក 2 ៖ ស្ថានភាពនិស្សិតមានការងារធ្វើក្នុងពេលសិក្សានៅសភភព

## ការប្រៀបធៀបអំពីស្ថានភាពការងារនិស្សិតក្រោយពេលបញ្ចប់ការសិក្សា

ការសិក្សាបានបង្ហាញថា៖ក្រុមនិស្សិតដែលបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩ និង២០២០កន្លងមក ទទួលបានការងារធ្វើ៩១% (n=866) បើធៀបមុនការចូលមកសិក្សានៅសភភពគឺមានកំណើន៧៤% តែបើធៀបក្នុងកំ

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

ឡុងពេលសិក្សានៅសកកពគឺមានកំណើន១៧% ក្នុងនោះកំណើនទទួលបានការងារពេញម៉ោងមានរហូតដល់ទៅ៧៥.៦%។ បើវិភាគពីលទ្ធភាពមានការងារទៅតាមឆ្នាំដែលបានបញ្ចប់ការសិក្សា បង្ហាញឲ្យឃើញថា និស្សិតដែលបានរៀនចប់ក្នុងឆ្នាំ២០១៩មានការងារស្ថិរភាព៩១.៩%(n=756)ក្នុងនោះការងារពេញម៉ោង ៨៨.៩% ចំណែកនិស្សិតដែលបានរៀនចប់ក្នុងឆ្នាំ២០២០មានការងារស្ថិរភាព៨៣.៦%(n=110)ក្នុងនោះការងារពេញម៉ោង៨១.៨%។ ជារួម ក្នុងចំណោមអ្នកមានការងារធ្វើ៩១% (n=866) ក្រោយបញ្ចប់ការសិក្សាទាំងនោះ មានអតីតនិស្សិតជាស្ត្រីមានទទួលបានការ៨៧.៧%(n=318) និងមានការងាររពេញម៉ោងចំនួន ៨៣.៦%(n=318)។

យោងតាមទិន្នន័យវិភាគ យើងអាចធ្វើការសន្និដ្ឋានថាបើនិស្សិតដែលបានបញ្ចប់ការសិក្សាមុនអាចមានលទ្ធភាពទទួលបានការងារស្ថិរភាពបានច្រើនជាង ហើយក៏អាចសន្និដ្ឋានដែរថានិស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ពិតជាអាចទទួលបានការងារស្ថិរភាពមួយពិតប្រាកដ។




ក្រាហ្វិក 3៖ លទ្ធភាពមានការងារធ្វើក្រោយបញ្ចប់ការសិក្សា

## រយៈពេលមានការងារធ្វើក្រោយពេលបញ្ចប់ការសិក្សា

តាមទិន្នន័យដែលផ្តល់ដោយអ្នកចូលរួមឆ្លើយសំណួរបង្ហាញថា ក្រុមអតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩និងឆ្នាំ២០២០(n=866) ភាគច្រើន៨៣.១% ទទួលស្គាល់ថាការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញអាចជួយពួកគាត់ឲ្យរកការងារបានក្នុងរយៈពេលមួយតិចជាង៣ខែមានចំនួន៦៧.៧% និងអ្នក

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

ចំណាយពេលរកការងារធ្វើក្នុងរយៈពេលចន្លោះពី៣ខែទៅ៦ខែមានចំនួន១៩.៣% ដោយឡែក ក្រុមនិស្សិតដែលបញ្ចប់ការសិក្សាមួយចំនួនតូចបានប្រើប្រាស់រយៈពេលច្រើនជាង៦ខែ ដើម្បីទទួលបានការងារធ្វើ។

## ស្ថាប័ននិស្សិតកំពុងបម្រើការងារក្រោយពេលបញ្ចប់ការសិក្សា

តាមការវិភាគលើទិន្នន័យដែលទទួលបានបង្ហាញលទ្ធផលថា ក្នុងចំណោមអ្នកមានការងារធ្វើពេញម៉ោងចំនួន៩១.៩%(n=756 អតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩) គឺមាននិស្សិត១១.២% បម្រើការងារក្នុងគ្រឹះស្ថានអប់រំសាធារណៈ និស្សិត១៤.២%បម្រើការងារក្នុងគ្រឹះស្ថានអប់រំឯកជន និស្សិត ៧.១% បម្រើការងារក្នុងស្ថាប័នរដ្ឋ និស្សិត៣.៨% បម្រើការងារក្នុងអង្គការមិនមែនរដ្ឋាភិបាល និស្សិត ៥១.១% បម្រើការងារក្នុងវិស័យឯកជននានា និង២.៦%មានជំនួញផ្ទាល់ខ្លួន។ ដោយឡែក សម្រាប់អតីតនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០២០ដែលមានការងារធ្វើពេញម៉ោងចំនួន៨៣.៦% (n=110) គឺមាននិស្សិត៨.២% កំពុងបម្រើការងារក្នុងគ្រឹះស្ថានអប់រំឯកជន និស្សិត៥.៥% បម្រើការងារក្នុងស្ថាប័នរដ្ឋ និស្សិត៦៩.១% កំពុងបម្រើការងារក្នុងផ្នែកឯកជននានា។ តាមការវិភាគលទ្ធផលនេះបង្ហាញថា និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញយ៉ាងច្រើនលើសលប់ គឺមានលទ្ធភាពរកការងារធ្វើបានច្រើនក្នុងវិស័យឯកជននានា។ ដូច្នេះ ការសិក្សានៅពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញមិនមែនសម្រាប់តែការបណ្តុះបណ្តាលគ្រូសម្រាប់វិស័យអប់រំប៉ុណ្ណោះទេ។ ក្រាហ្វិកតំណាងនិស្សិតឆ្នាំ២០១៩ និង២០២០។




ក្រាហ្វិក 4 ៖ ស្ថាប័នដែលនិស្សិតកំពុងធ្វើការងារក្រោយបញ្ចប់ការសិក្សា

## ប្រាក់បៀវត្សទទួលបានប្រចាំខែ

តាមការផ្តល់ចម្លើយរបស់អ្នកចូលរួមបំពេញសំណួរបានបញ្ជាក់ឱ្យដឹងថា ក្រោយពេលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និស្សិតទទួលប្រាក់បៀវត្សតិចជាង២០០ដុល្លាមានចំនួន៦.៧% ប្រាក់បៀវត្សចាប់ពី២០០ដុល្លា ដល់៤០០ដុល្លា មានចំនួន៦០.៧% ប្រាក់បៀវត្សចាប់ពី៤០១ដុល្លា ដល់៦០០

*Insight: Cambodia Journal of Basic and Applied Research*, Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

ដុល្លា មានចំនួន១៨.៧% ប្រាក់បៀវត្សចាប់ពី៦០១ដុល្លា ដល់៨០០ដុល្លា មានចំនួន៣.៨% ប្រាក់បៀវត្សចាប់ពី៨០១ដុល្លា ដល់១០០០ដុល្លា មាន១.៣% និងប្រាក់បៀវត្សច្រើនជាង១០០០ដុល្លា មាន២.២% ។ ក្នុងនោះនិស្សិតដែលមានប្រាក់បៀវត្សខ្ពស់ជាងគេគឺនិស្សិតដែលបានបញ្ចប់ការសិក្សាផ្នែកព័ត៌មានវិទ្យា។ គួរកត់សម្គាល់ដែរថា និស្សិតភាគច្រើនដែលទទួលបានប្រាក់បៀវត្សចន្លោះពី២០០ដុល្លា ដល់៤០០ដុល្លា ដែលមានចំនួនរហូតដល់ជាង៦០.៧%នោះ គឺជាកត្តាស្វែងយល់បន្ថែមពីស្ថានភាពបៀវត្សទូទៅក្នុងប្រទេសកម្ពុជា ហើយកត្តាដែលជួយជម្រុញឲ្យទទួលបានបៀវត្សខ្ពស់ គឺអាស្រ័យលើប្រភេទការងារផងដែរ។




ក្រាហ្វិក 5 ៖ ស្ថានភាពប្រាក់បៀវត្សដែលនិស្សិតទទួលបាន

## ការប្រៀបធៀបប្រាក់បៀវត្សប្រចាំខែ

តាមការវិភាគលើទិន្នន័យដែលទទួលបានបង្ហាញលទ្ធផលថា ក្រុមនិស្សិតដែលមានប្រាក់បៀវត្សខ្ពស់គឺក្រុមនិស្សិតដែលបានបញ្ចប់ការសិក្សាក្នុងឆ្នាំ២០១៩។ លើសពីនេះទិន្នន័យក៏បានបង្ហាញដែលថា ការទទួលបានបៀវត្សគឺមិនអាស្រ័យលើភេទរបស់និស្សិតប្រុសឬស្រីទេ ហើយក៏មិនមានការខុសគ្នារវាងនិស្សិតទទួលបានអាហារូបករណ៍ ឬក៏សិក្សាបង់ថ្លៃដែរ។

តារាង 1 ៖តារាងប្រៀបធៀបប្រាក់បៀវត្ស

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

| ឯកទេសជំនាញ | ប្រាក់បៀវត្ស (US$) | | | |
|---|---|---|---|---|
| | ចន្លោះពី $401 ដល់$600 | ចន្លោះពី $601 ដល់$800 | ចន្លោះពី $801 ដល់$1000 | ច្រើនជាង $1,000 |
| ព័ត៌មានវិទ្យា | ៦០.៥% | ៦៥.៥% | ៦០% | ៥០% |
| វិស្វកម្មព័ត៌មានវិទ្យា | ៤.៣% | ៦.៩% | ១០% | ៦.៣% |
| ពាណិជ្ជ.អន្តរជាតិ | ៣.៧% | ១០.៣% | ០.០% | ១២.៥% |
| | n=162 | n=59 | n=29 | n=16 |

## ៣.៨ មធ្យោបាយស្វែងរកការងារធ្វើ

ការប្រមូលទិន្នន័យអំពីរបៀបអតីតនិស្សិតស្វែងរកការងារធ្វើ គឺក្នុងគោលបំណងពិនិត្យមើលប្រសិទ្ធភាពលើយន្តការផ្ដល់សេវាកម្មដែលមានស្រាប់របស់គ្រឹះស្ថាន និងមធ្យោបាយផ្សេងៗដែលនិស្សិតប្រើប្រាស់ដើម្បីទទួលបានការងារធ្វើ។ តាមទិន្នន័យដែលទទួលបានបង្ហាញលទ្ធផលថា និស្សិតភាគច្រើនមិនបានប្រើប្រាស់សេវាកម្មដែលផ្ដល់ដោយគ្រឹះស្ថានទេ ហើយមធ្យោបាយដែលនិស្សិតរកការងារធ្វើច្រើនជាងគេ គឺតាមរយៈការទទួលព័ត៌មានពីសាច់ញាតិឬមិត្តភ័ក្ដ៣៤.១% តាមប្រព័ន្ធអ៊ីនធឺណែត២១.១% និងការប្រឡងក្របខណ្ឌ ២០.៨%។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh




ក្រាហ្វិក 6 ៖ មធ្យោបាយរកការងារធ្វើក្រោយបញ្ចប់ការសិក្សា

## ទស្សនៈនិស្សិតអំពីចំណេះដឹងនិងអាជីព

ដើម្បីស្ទាបស្ទង់ទស្សនៈនិស្សិតអំពីការប្រើប្រាស់ចំណេះដឹងជំនាញ និងអាជីពមានទំនាក់ទំនងនិងសារៈសំខាន់ជាមួយគ្នាក្នុងកម្រិតណាសម្រាប់ការងារដែលពួកគេកំពុងធ្វើបច្ចុប្បន្ន អ្នកចូលរួមត្រូវផ្ដល់ពិន្ទុចាប់ពី១ពិន្ទុ(មិនមានសារៈសំខាន់ទាល់តែសោះ) រហូតដល់៥ពិន្ទុ(មានសារៈសំខាន់ខ្លាំងណាស់)។ តាមការប្រមូលទិន្នន័យអំពីទស្សនៈអតីតនិស្សិតបានបង្ហាញឲ្យឃើញថា និស្សិត៦៨.២%(n=866)ទទួលស្គាល់ថាចំណេះដឹងនិងជំនាញដែលទទួលបានពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានសារៈសំខាន់ខ្លាំងណាស់ និងនិស្សិត ៧៥.៥% (n=866)ទៀត បានវាយតម្លៃថាការសិក្សានៅទីនេះមានសារៈសំខាន់ខ្លាំងក្នុងការតម្រង់ទិសនិស្សិតឲ្យទទួលបានអាជីពបច្ចុប្បន្ន។

ដោយឡែកតាមការវិភាគទិន្នន័យដដែល និស្សិតចំនួន៨៣.៦% ($r=0.534^{**}$)យល់ឃើញថាការសិក្សានៅពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញគឺបានផ្សារភ្ជាប់ទ្រឹស្ដីទៅនឹងការអនុវត្ត ដែលជាកត្តាធ្វើនិស្សិតចំនួន៨០.១% ($r=0.691^{**}$)មានសមត្ថភាពគ្រប់គ្រាន់ក្នុងការប្រើប្រាស់ចំណេះដឹងនិងជំនាញដែលទទួលបានពីការសិក្សាទៅប្រតិបត្តិក្នុងការបំពេញការងារបច្ចុប្បន្ន ហើយជំនាញដែលបានសិក្សាកន្លងមកមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយការងារដែលពួកកាត់កំពុងធ្វើ ឬអាចនិយាយបានថានិស្សិតចំនួន៧៧.៥%($r=0.690^{**}$)កំពុងធ្វើការត្រូវតាមជំនាញ។ កត្តាចំបងទាំងនេះគឺជាចំណុចគន្លឹះដែលបានជួយឲ្យនិស្សិតដែលបានបញ្ចប់កាសិក្សាទាំងនោះមានឱកាសទទួលបានការងារស្ថិរភាពមួយសមស្រប។ ក្នុងនោះភាសាអង់គ្លេសក៏ជាកត្តាមូលដ្ឋាន

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

មួយសម្រាប់និស្សិតបំពេញការងារ ហើយក៏ជាកត្តាដែលគ្រឹះស្ថានត្រូវយកចិត្តទុកដាក់ក្នុងការបង្កើនសមត្ថភាពនិស្សិត និងឱកាសការងារទីផ្សារ។




ក្រាហ្វិក 7 ៖ ទំនាក់ទំនងការសិក្សានិងជំនាញក្នុងការងារទីផ្សារ

## ទំនាក់ទំនងកម្មវិធីសិក្សា និងក្របខណ្ឌគុណវុឌ្ឍិជាតិ

នៅក្នុងក្របខណ្ឌគុណវុឌ្ឍិជាតិ គឺតម្រូវឲ្យកម្មវិធីថ្នាក់បរិញ្ញាបត្រមានរំលេចនូវ ចំណេះដឹង ជំនាញក្នុងការគិត ជំនាញទំនាក់ទំនងអន្តរបុគ្គល និងការទទួលខុសត្រូវ ជំនាញលេខនព្វន្ត ព័ត៌មានវិទ្យា និងទំនាក់ទំនង ជំនាញចិត្តចលនា។ តារាងខាងក្រោមបង្ហាញពីភាពឆ្លើយតបក្របខណ្ឌគុណវុឌ្ឍិជាតិ។

តារាង 2 ៖ ទំនាក់ទំនងកម្មវិធីសិក្សានិងក្របខណ្ឌគុណវុឌ្ឍិ

| ១=មិនសំខាន់ទាល់តែសោះ ៥=សំខាន់ខ្លាំងណាស់ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| មុខវិជ្ជាទាំងអស់ដែលអ្នកសិក្សាមានប្រយោជន៍ចំពោះអាជីពអ្នកខ្លាំងណាស់ | 4.2% | 11.3% | 26.8% | 25.5% | 32.3% |
| ចំណេះដឹងដែលអ្នកទទួលបានពីស.ភ.ភ.ព.កំពុងជាតម្រូវការចាំបាច់ក្នុងសង្គមកម្ពុជា | 2.3% | 6.8% | 22.7% | 28.8% | 39.4% |
| ការសិក្សានៅស.ភ.ភ.ព.ជួយអ្នកឲ្យមានសមត្ថភាពវិភាគ និងដោះស្រាយបញ្ហាប្រឈមនានាក្នុងការងារ | 4.0% | 10.2% | 29.7% | 29.8% | 26.3% |
| ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពទំនាក់ទំនងការងារល្អ | 4.3% | 10.0% | 30.4% | 27.0% | 27.4% |

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

| ១=មិនសំខាន់ទាល់តែសោះ ៥=សំខាន់ខ្លាំងណាស់ | ១ | ២ | ៣ | ៤ | ៥ |
|---|---|---|---|---|---|
| ការសិក្សានៅស.ភ.ភ.ព.បានជួយឲ្យអ្នកមានសមត្ថភាពច្នៃប្រឌិត | 3.7% | 11.8% | 33.6% | 28.1% | 22.9% |
| អ្នកមានសមត្ថភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័តមាន ( ICT ) | 2.9% | 10.3% | 27.3% | 28.4% | 31.2% |
| ចំណេះនិងជំនាញរបស់អ្នកអាចជួយអ្នកបង្កើតសហគ្រិនភាពផ្ទាល់ខ្លួន | 3.1% | 11.1% | 35.5% | 22.4% | 27.9% |
| អ្នកពេញចិត្តជាមួយចំណេះដឹងនិងគុណភាពអប់រំដែលអ្នកបានទទួលពី ស.ភ.ភ.ព. | 3.6% | 10.2% | 27.4% | 32.1% | 26.8% |

**សម្គាល់៖** ការផ្តល់តម្លៃត្រឹមលេខ៣មានន័យថាដូចការរំពឹងទុក លេខ៤មានន័យថាលើសការរំពឹងទុក ហើយលេខ៥មានន័យថាមានលក្ខណៈពិសេស។

## ចំណាចបន្តការសិក្សា

តាមទិន្នន័យដែលទទួលបានបង្ហាញថា និស្សិតដែលបានបញ្ចប់ការសិក្សា(n=866)ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញប្រមាណជា១០.៧% បានបន្តកាសិក្សានៅNIE និងអ្នកដែលបន្តរៀនថ្នាក់បរិញ្ញាបត្រលើឯកទេសផ្សេងឬគ្រឹះស្ថានផ្សេងចំនួន៦.៥%។ អ្នកបានបន្តសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់៧.៨% និងអ្នកបន្តយកថ្នាក់បណ្ឌិត០.២%។

អតីតនិស្សិតទាំងអស់នោះក៏មានបំណងចង់ត្រឡប់មកបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានចំនួន១៥.១% ក្នុងចំណោមអ្នកដែលចង់បន្តកាសិក្សាក្នុងស្រុកមាន១៨% និងចង់សិក្សានៅបរទេស៥០.២% ។ និស្សិតដែលបានបន្តការសិក្សាទាំងនោះគឺទទួលបានអាហារូបករណ៍ចំនួន៦.១% និងសិក្សាបង់ថ្លៃចំនួន៨.៥%។

*Insight: Cambodia Journal of Basic and Applied Research,* Volume 2 No. 1 (2020)
© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh




ក្រាហ្វិក 8 ៖ គោលបំណងបន្តការសិក្សា

## សេចក្តីសន្និដ្ឋាន

ដោយសង្ខេបនិស្សិតបញ្ចប់ការសិក្សាភាគច្រើនលើសលប់មានអាជីពមួយច្បាស់លាស់ ហើយបានទទួលស្គាល់ថាចំណេះដឹង ជំនាញ និងគុណតម្លៃ ដែលពួកគេទទួលបានពីការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានជួយដល់ការស្វែងរកនិងបំពេញការងារមួយយ៉ាងពិតប្រាកដ។ សេចក្តីសន្និដ្ឋានទាំងឡាយខាងក្រោមគឺបង្ហាញអំពីគុណភាពនៃកម្មវិធីសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញដែលឆ្លើយតបនឹងតម្រូវការជំនាញទីផ្សារការងារ និងសង្គមកម្ពុជា។ ជាពិសេសនោះ អ្វីដែលគួរឲ្យចំណាប់អារម្មណ៍នោះគឺនិស្សិតដែលបញ្ចប់បរិញ្ញាបត្រហើយចង់វិលមកសិក្សាបរិញ្ញាបត្រជាន់ខ្ពស់លើមុខជំនាញដដែលនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញវិញ ហើយនិស្សិត៨៧.៤%ចង់ឲ្យនិស្សិតជំនាន់ក្រោយៗសិក្សាមុខជំនាញដូចខ្លួនឲ្យបានច្រើន។ ដោយផ្អែកលើរបកគំហើញដែលបរិយាយពីខាងលើ យើងអាចទាញការសន្និដ្ឋានអំពីលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតដែលបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញដូចខាងក្រោម៖

- សាកលវិទ្យាល័យភូមិន្ទភ្នំពេញនៅតែជាកន្លែងបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព និងសមត្ថភាព ជាទីទំនុកចិត្តសម្រាប់រួមចំណែកបង្កើនសមិទ្ធផលដល់សេដ្ឋកិច្ចសង្គម។
- និស្សិតដែលបានបញ្ចប់ការសិក្សាពីគ្រឹះស្ថានជាតិមួយនេះមានលទ្ធភាពនិងឱកាសច្រើនក្នុងការទទួលបានការងារមួយអចិន្ត្រៃយ៍ បើទោះបីគ្រឹះស្ថាននេះធ្លាប់គេសន្និដ្ឋានថាកន្លែងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់វិស័យអប់រំក៏ពិតមែន ប៉ុន្តែតាមសិក្សាស្រាវជ្រាវនេះបានបង្ហាញយ៉ាងច្បាស់ថា

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

ក្រៅពីក្លាយជាអ្នកអប់រំ និស្សិតដែលបានបញ្ចប់ការសិក្សាពីទីនេះអាចទទួលបានការងារសមស្របនៅតាមស្ថាប័នឯកជន ឬក្រុមហ៊ុននានា។

- ក្រៅពីបង្កើនសមត្ថភាពដល់អ្នកសិក្សាក្នុងបំណិនឯកទេស សាកលវិទ្យាល័យអាចផ្តល់បំណិនជីវិតខាងឥរិយាបថដែលជួយឲ្យនិស្សិតមានសមត្ថភាពទន់ភ្លន់ បត់បែន ចេះទទួលខុសត្រូវលើការងារ មានទំនុកចិត្តលើខ្លួនឯង មានសមត្ថភាពដោះស្រាយបញ្ហារ ធ្វើការងារជាក្រុម មានគំនិតច្នៃប្រឌិត មានឆន្ទៈរៀនសូត្រ តស៊ូអត់ធ្មត់និងភាពជាអ្នកដឹកនាំ ដែលកក្តាទាំងអស់នេះសុទ្ធតែជាជំនាញទន់ដែលមិនអាចខ្វះបានក្នុងការបំពេញកិច្ចការងារ។
- បន្ថែមលើការផ្តល់ចំណេះដឹងនិងសមត្ថភាពប្រកបដោយនិរន្តរភាពដល់និស្សិត កម្មវិធីសិក្សារបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញមានលក្ខណៈស្តង់ដា ស្របទៅនឹងក្របខណ្ឌគុណវុឌ្ឍិជាតិ និងឆ្លើយតបនិងតម្រូវការទីផ្សារការងារ។

ដោយផ្អែកទៅលើយន្តការវិភាគនិងប្រមូលទិន្នន័យ និងការចូលរួមផ្តល់ព័តមានពីអ្នកចូលរួមក្នុងការស្រាវជ្រាវនេះ យើងសូមផ្តល់អនុសាសន៍មួយចំនួនដូចខាងក្រោម៖

- គ្រឹះស្ថានត្រូវរៀបចំកែលម្អយន្តការផ្តល់សេវានិស្សិត ដូចជាផ្នែកការិយាល័យប្រឹក្សាការងារសកភព សមាគមន៍និស្សិត និងការផ្សព្វផ្សាយព័ត៌មានការងារ
- កសាងទំនាក់ទំនងល្អជាមួយបណ្តានិយោជកតាមស្ថាប័នឯកជន ឬក្រុមហ៊ុន ជាកន្លែងដែលអតីតនិស្សិតធ្លាប់ធ្វើការ ឬកំពុងធ្វើ ដើម្បីសិក្សាអំពីការងារទីផ្សារស៊ីជម្រៅ
- ត្រូវសិក្សាបន្ថែមអំពីកម្រិតប្រាក់ខែនិងប្រភេទភារកិច្ចនិងតួនាទី និងស្វែងរកមូលហេតុប្រាក់បៀវត្សមានកម្រិត ដោយត្រូវសិក្សាលើគំរូសំណាកនេះឡើងវិញនៅក្នុងរយៈពេល៥ឆ្នាំក្រោយ
- បន្តការសិក្សាស្រាវជ្រាវអំពីស្ថានភាពនិស្សិតក្រោយការបញ្ចប់ការសិក្សាឲ្យបានស៊ីជម្រៅ ពោលគឺមានភាគីនិយោជកដែលប្រើប្រាស់និស្សិតសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មកចូលរួមផ្តល់ព័ត៌មាន ឬកម្មវិធីសិក្សានីមួយៗត្រូវធ្វើការសិក្សាបែបនេះដោយខ្លួនឯងជាបន្តទៀត
- ប្រមូលរក្សាទុកទិន្នន័យនិស្សិតគ្រប់ជំនាន់ដើម្បីសិក្សាពីប្រសិទ្ធភាពនិងប្រសិទ្ធផលលើធនធានដែលបានបណ្តុះបណ្តាល
- គួរកែលម្អកម្មវិធីសិក្សាឲ្យមានល្អដើម្បីទាក់ទាញចំណាប់អារម្មណ៍និស្សិត និងស្របតាមតម្រូវការការងារទីផ្សារ។

© 2020 The Authors
© 2020 Research Office, Royal University of Phnom Penh

# ឯកសារយោង

លី មុនីរិទ្ធិ "របាយការណ៍ស្ដីពីកាសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិតបញ្ចប់ឆ្នាំ២០០៥" ផ្នែកធានាគុណភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០០៧(មិនមានបោះពុម្ព)

រ័ត្ន ឆាង "របាយការណ៍ស្ដីពីកាសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត" ផ្នែកធានាគុណភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០០៤(មិនមានបោះពុម្ព)

វង់ ឆវី "របាយការណ៍ស្ដីពីកាសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត" ផ្នែកធានាគុណភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០១០(មិនមានបោះពុម្ព)

វង់ ឆវី "របាយការណ៍ស្ដីពីកាសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត" ផ្នែកធានាគុណភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០១២

វង់ ឆវី "របាយការណ៍ស្ដីពីកាសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត" ផ្នែកធានាគុណភាពសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០១៥

អនាមិក "របាយការណ៍ស្ដីពីកាសិក្សាលើលទ្ធភាពស្វែងរកការងារធ្វើរបស់និស្សិត" វិទ្យាស្ថានភាសាបរទេស សាកលវិទ្យាល័យភូមិន្ទភ្នំពេញ២០០៤(មិនមានបោះពុម្ព)